ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ :៤០៧ អយក-ប្រក

# ប្រកាស

## ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា អលង្កែរ

### ឧបនាយករដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ១០៩៤-៥០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញអនុក្រឹត្យលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ១២ ឆ្នាំ

-បានឃើញអនុក្រឹត្យលេខ ជស-រកត ០៨៩៧-១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី២៣-៣-៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតលេខ របស់នាយកសាលាបឋមសិក្សា អលង្កែរ ចុះថ្ងៃទី ១៧ ខែ ៧ ឆ្នាំ ២០០១ ដោយចំណារឯកភាព របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ឆ្នាំង ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០២ ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

### សម្រេច

**ប្រការ១** :- ប្តូរឈ្មោះសាលាបឋមសិក្សា **អលង្កែរ** មកជាសាលាបឋមសិក្សា **ឯកសីផល** ដែលមានទីតាំងស្ថិតនៅភូមិ **អលង្កែរ** ឃុំ **តោងតោង** ស្រុក **ទឹកផុស** ខេត្ត **កំពង់ឆ្នាំង** ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ឆ្នាំង** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **ទឹកផុស** នាយកសាលាបឋមសិក្សា **ឯកសីផល** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម_សិទ្ធី**

<u>**កន្លែងទទួល**</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាបជាពត៌មាន "

- សាលាខេត្ត កំពង់ឆ្នាំង

" ជូនជ្រាបជាពត៌មាន "

- ដូចប្រការ ៣
- កាលប្បវត្តិ
- ឯកសារ នា -ប.ម